ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Mar-2013, 15:33
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

ផ្ញើជូនៈ ការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៣

ចម្លងជូនៈ ចៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល និងសហមេធាវីការពារក្តី នួន ជា

ផ្ញើពីៈ ឯកឧត្តម គង់ ស្រីម ប្រធានអង្គជំនុំជម្រះតុលាការកំពូល

កម្មវត្ថុៈ សំណើសុំព័ត៌មានទាក់ទងនឹងកិច្ចស៊ើបអង្កេតនៅក្នុងការជ្រៀតជ្រែកចូលក្នុងសំណុំរឿង ០០៣ និង ០០៤

អង្គជំនុំជម្រះតុលាការកំពូលទទួលបាន“បណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំចំណាត់ការបន្ទាន់តាម ៣៥ នៃវិធានផ្ទៃក្នុង” ដែលបានដាក់ដោយមេធាវីការពារក្តី នួន ជា (“មេធាវីការពារក្តី”) នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ (“បណ្តឹងសាទុក្ខ”),[1] ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធសំណើរបស់មេធាវីការពារក្តីសុំបើកការស៊ើបអង្កេតលើការជ្រៀតជ្រែករបស់រដ្ឋាភិបាលដែលត្រូវបានចោទប្រកាន់[2]។

បណ្តឹងសាទុក្ខនេះ ផ្អែកលើការចោទប្រកាន់អំពីការជ្រៀតជ្រែកចូលក្នុងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤ ដែលតាមការអះអាងនៅពុំទាន់បានដោះស្រាយ ហើយមានការប៉ះពាល់ដល់ភាពយុត្តិធម៌នៃសំណុំរឿង ០០២។ ក្នុងចំណោមការចោទប្រកាន់ដទៃទៀតនោះ មេធាវីការពារក្តី យោងទៅលើកាលៈទេសៈដែល

---

[1] ឯកសារលេខ E189/3/1/1។

[2] សេចក្តីសម្រេចលើសំណើសុំចាត់វិធានការជាបន្ទាន់ អនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុងឯកសារលេខ E189/3, ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ និងដាក់នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២, ការសម្រេចលើសំណើសុំចំណាត់ការជាបន្ទាន់ ដោយអនុលោមតាម វិធាន ៣៥ នៃវិធានផ្ទៃក្នុង ឯកសារលេខ E189, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១២។

បានលើកឡើងដោយចៅក្រម Laurent KASPER-ANSERMET ដែលជាមូលហេតុចំពោះការលាលែងរបស់គាត់[3]។

អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ដើម្បីជាការសមស្របសម្រាប់ការជំនុំជម្រះត្រឹមត្រូវលើបណ្តឹងសាទុក្ខនេះ ខ្លួនត្រូវតែទទួលបានព័ត៌មាន ប្រសិនបើមាន នូវចំណាត់ការជាផ្លូវអ្វីខ្លះ ដែលបានធ្វើឡើងក្នុងការឆ្លើយតបទៅនឹងការចោទប្រកាន់នៃការជ្រៀតជ្រែកក្នុងសំណុំរឿង ០០៣ និង ០០៤ ជាពិសេសទាក់ទងទៅនឹងកិច្ចស៊ើបសួរតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង។ ពាក់ព័ន្ធចំណុចនេះ អង្គជំនុំជម្រះតុលាការកំពូល ស្នើសុំសហចៅក្រមស៊ើបអង្កេតផ្តល់ព័ត៌មាន ដែលខ្លួនយល់ថាសមស្រប ដោយពិចារណាទៅលើភាពសម្ងាត់នៃកិច្ចដំណើរការនីតិវិធី និងផលប្រយោជន៍ស្របច្បាប់ដទៃទៀត ដោយភ្ជាប់មកជាមួយនូវព័ត៌មានស្តីពីចំណាត់ការដែលបានធ្វើឡើង និងលទ្ធផលនៃចំណាត់ការនេះ។

ព័ត៌មានខាងលើ គប្បីផ្តល់ត្រឹមថ្ងៃ ចន្ទ ទី ១១ ខែ មីនា ឆ្នាំ ២០១៣។

---

[3] កំណត់ហេតុរបស់ចៅក្រមបម្រុងអន្តរជាតិ ផ្ញើទៅភាគីស្តីពីដំណើរការមិនប្រក្រតីនៅក្នុង អ.វ.ត.ក កើតឡើងចំពោះកិច្ចស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ ឯកសារលេខ D38 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ និងបានដាក់នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១២ ទំព័រ ១៣ ("កើតមានឡើងនៅក្នុង អ.វ.ត.ក ភាពមិនប្រក្រតីដ៏ធ្ងន់ធ្ងរ ភាពមិនបំពេញតួនាទី និងការរំលោភលើដំណើរការនីតិវិធីដ៏ត្រឹមត្រូវ ដែលប៉ះពាល់ដល់កិច្ចដំណើរការនៃច្បាប់ និងប៉ះពាល់ដល់កិច្ចស៊ើបអង្កេតត្រឹមត្រូវនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ចាប់តាំងពីសំណុំរឿងនេះមកដល់ការិយាល័យ")។